ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
សំណុំរឿងព្រហ្មទណ្ឌលេខ ៧១៣ អ.ក
ចុះថ្ងៃ២៧ ខែឧសភា ឆ្នាំ២០២២
សាលក្រមលេខ: ៥៦/ឝ
ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤

# នាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការលេខ៣ នៃសាលាដំបូងខេត្តកណ្ដាល នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ៩ព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៧១៣ អក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ប៊ុន ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរអ្នករកស៊ី ទីកន្លែងកំណើត និងលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] បេន (ស្លាប់) ម្ដាយឈ្មោះ [redacted] តូច (រស់) នៅលីវ កម្រិតវប្បធម៌បរិញ្ញាបត្រ ជានីតិជន ទោសពីមុន គ្មាន។ (ក្រៅឃុំ)

២-ឈ្មោះ [redacted] សុភ័ក្រ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] អៀន (រស់) ម្ដាយឈ្មោះ [redacted] ស្រ៊ាន (រស់) នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី០៦ ជានីតិជន ទោសពីមុន គ្មាន។ (ក្រៅឃុំ)

៣-ឈ្មោះ [redacted] អៀន ភេទប្រុស អាយុ៦១ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សុខ (ស្លាប់) ម្ដាយឈ្មោះ [redacted] កេង (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ស្រ៊ាន (រស់) មានកូន០៦នាក់ ជានីតិជន ទោសពីមុន គ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ: ហិង្សាដោយចេតនា(ទៅវិញទៅមក) ប្រព្រឹត្តនៅភូមិក្រាំងចេក ឃុំដើមឬស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ១០៣២ ដកសព ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញដីកាដំណោះស្រាយលេខ: ១០៦០ ដកដស ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ១១៥៥ ដកចត/២៣ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល។

**អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១១ និង០០នាទី ឈ្មោះ [redacted] ប៊ុន បានជិះម៉ូតូមកផ្ទះរបស់ឈ្មោះ [redacted]



Scanned with CamScanner

អៀន ដើម្បីទារលុយថ្លៃកុំមីស្យុងដីចំនួន ១០០$ (មួយរយដុល្លារអាមេរិក) ប៉ុន្តែឈ្មោះ [redacted] អៀន មិនព្រមឱ្យ ហើយឈ្មោះ [redacted] ប៊ុន ក៏បានទាញទូរស័ព្ទមកថតឈ្មោះ [redacted] អៀន។ ខណៈពេលនោះឈ្មោះ [redacted] អៀន ក៏បានចាប់ទូរស័ព្ទរបស់ឈ្មោះ [redacted] ប៊ុន មកបោកទៅលើដី និងបានទាត់ឈ្មោះ [redacted] ប៊ុន ចំនួនបីជើងចំខ្នង ចំណែកឈ្មោះ [redacted] ប៊ុន ក៏បានប្រតាយប្រតប់គ្នាជាមួយឈ្មោះ [redacted] អៀន បណ្តាលឱ្យឈ្មោះ [redacted] អៀន រងរបួសដៃឆ្វេងហូរឈាម។ ឃើញដូច្នេះឈ្មោះ [redacted] សុភ័ក្រ ត្រូវជាកូនប្រុសឈ្មោះ [redacted] អៀន ក៏បានចូលវាយឈ្មោះ [redacted] ប៊ុន ហើយអ្នកទាំងពីរនាក់ក៏បានប្រតាយប្រតប់គ្នាទៅវិញទៅមក បណ្តាលឱ្យរងរបួសរៀងខ្លួន។ បន្ទាប់ក៏មានអ្នកចូលទៅឃាត់បំបែកចេញតែម្តង។

<u>**ពេលសវនាការ**</u>

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានទៅទារលុយកម្រៃជើងសារថ្លៃដីចំនួន ១០០$ ដែលជួយរកអ្នកទិញដីឱ្យឈ្មោះ [redacted] អៀន ប៉ុន្តែគាត់មិនបានឱ្យខ្លួនទេ ថែមទាំងបានជេរខ្លួនថា "អារកស៊ីបោកគេ" និងជេរដល់ម្តាយរបស់ខ្លួនផងដែរ។ បន្ទាប់មកក៏មានការទាស់ពាក្យសម្តីគ្នា ដោយឈ្មោះ [redacted] សុភ័ក្រ ជាកូនបានវាយខ្លួនត្រូវដៃ និងទ្រូង ចំណែកឈ្មោះ [redacted] អៀន ជាឪពុកបានទាត់ខ្លួនពីក្រោយ។ ឃើញដូចនេះខ្លួនក៏យកទូរស័ព្ទមកថតសកម្មភាពរបស់ពួកគាត់។ ខ្លួនមិនបានវាយអ្នកទាំងពីរនាក់នោះទេ។ សុំទាមទារសំណងជម្ងឺចិត្តចំនួន ២ម៉ឺនដុល្លារអាមេរិក ពីឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន។

-ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ បានឆ្លើយថា៖ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ ខ្លួនបានឃើញឈ្មោះ [redacted] ប៊ុន ជិះម៉ូតូចូលមកផ្ទះខ្លួនដើម្បីទារលុយកម្រៃជើងសារចំនួន ១០០$ ពីឪពុកខ្លួនឈ្មោះ [redacted] អៀន តែគាត់មិនឱ្យ។ បន្ទាប់មកក៏មានការទាស់ពាក្យសម្តីគ្នា។ ក្រោយមកឈ្មោះ [redacted] ប៊ុន បានយកទូរស័ព្ទមកថតសកម្មភាពក្នុងផ្ទះរបស់ខ្លួន ហើយឪពុកក៏បានរារាំងមិនឱ្យថត។ ពេលនោះឈ្មោះ [redacted] ប៊ុន ក៏បានប្រើហិង្សាមកលើឪពុកខ្លួន ចំណែកខ្លួន និងអ្នកជិតខាងឈ្មោះ [redacted] អៀន ក៏បានចូលឃាត់ ហើយរឿងនេះក៏បានបញ្ចប់។ ខ្លួនមិនបានប្រើអំពើហិង្សាលើឈ្មោះ [redacted] ប៊ុន ទេ។ ក្នុងរឿងនេះខ្លួនសុំទាមទារសំណងជម្ងឺចិត្ត និងការខូចខាត ចំនួន ៤០ លានរៀល ពីឈ្មោះ [redacted] ប៊ុន។

-ជនជាប់ចោទឈ្មោះ [redacted] អៀន បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយខ្លួនក៏អត់បានវាយឈ្មោះ [redacted] ប៊ុន ដែរ។ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១១ព្រឹក ខ្លួនបានឃើញឈ្មោះ [redacted] ប៊ុន ជិះម៉ូតូចូលមកផ្ទះខ្លួនដើម្បីទារលុយកម្រៃជើងសារចំនួន ១០០$ ពីខ្លួនតែខ្លួនមិនឱ្យព្រោះម្ចាស់ដីបានមកពីទិញពីខ្លួនផ្ទាល់ គឺមិនមានទំនាក់ទំនងជាមួយឈ្មោះ [redacted] ប៊ុន ទេ។ ដោយឮខ្លួននិយាយបែបនេះឈ្មោះ [redacted] ប៊ុន ក៏ខឹងហើយជេរគំរាមខ្លួន និងបានយកទូរស័ព្ទមកថតសកម្មភាពក្នុងផ្ទះរបស់ខ្លួន តែខ្លួនឃាត់ រហូតដល់មានការប្រតាយប្រតប់គ្នា និងបានកោសដៃរបស់ខ្លួននឹងនាឡិការបស់ឈ្មោះ [redacted] ប៊ុន បណ្តាលឱ្យចេញឈាម។ ក្រោយកើតហេតុឈ្មោះ [redacted] ប៊ុន ក៏បានជិះម៉ូតូទៅផ្ទះវិញបាត់ទៅ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] អ៊ាន នៅដំណាក់កាលអយ្យការ បានឆ្លើយថា៖ កាលពីថ្ងៃមិនចាំ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១១ព្រឹក ខ្លួនបានដើរទៅលេងផ្ទះរបស់ឈ្មោះ [redacted] អៀន។ ពេលនោះខ្លួនបានឃើញឈ្មោះ [redacted] ប៊ុន បានយកទូរស័ព្ទមកថតបរិវេណផ្ទះរបស់ឈ្មោះ [redacted] អៀន ហើយឈ្មោះ [redacted] អៀន ក៏បានចូលទៅឃាត់ តែត្រូវបានឈ្មោះ [redacted] ប៊ុន ដាល់មួយដៃ ឃើញដូច្នេះខ្លួន និងឈ្មោះ [redacted] សុភ័ក្រ ក៏ចូលទៅឃាត់។ ចំណែកឈ្មោះ [redacted] ប៊ុន ក៏ត្រឡប់ទៅផ្ទះវិញទៅ។

-ក្រឡាបញ្ជីអាន: ឯកសារនានាក្នុងសំណុំរឿង។

<u>**សិទ្ធិនិយាយស្តីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**</u>

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖ សុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ: ១០៣២ ដកសព ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្ញុំបាទមិនបានវាយទៅលើឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន ឡើយ។ កូនក្តីខ្ញុំបាទថតរូបគឺដើម្បីទាមទារឱ្យអ្នកទាំងពីរប្រគល់ប្រាក់កម្រៃជើងសារមកឱ្យកូនក្តីរបស់ខ្លួន។ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនបានរួចផុតបទចោទប្រកាន់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខភ័ក្រ និងឈ្មោះ [redacted] អៀន បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ឈ្មោះ [redacted] ប៊ុន បានវាយកូនក្តីរបស់ខ្លួនទាំងពីរនាក់។ កាលដែលឈ្មោះ [redacted]



Scanned with CamScanner

ប៊ុន ថាវាយគាត់ត្រូវដៃ គឺឈ្មោះ [redacted] អៀន មិនអាចវាយបានទេ ព្រោះគាត់មានវ័យចំណាស់ហើយដែរ។ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនបានរួចផុតបទចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន, ឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន បានធ្វើការកត់សម្គាល់ដូចគ្នាថា៖ សូមឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្ញុំបាទផង។

<u>ផ្អែកតាមលទ្ធផល នៃកិច្ចពិភាក្សាដេញដោល</u>

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុន, ឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] អ៊ាន។

-ក្រោយពីបានស្តាប់ការអានឯកសារនានា ។

-ក្រោយពីបានពិនិត្យឯកសារនានាកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

<u>សំអាងហេតុ</u>

<u>តុលាការយល់ឃើញថា:</u>

១-កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១១ និង ០០នាទី ពិតជាមានករណី: ហិង្សាដោយចេតនា(ទៅវិញទៅមក) ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ប៊ុន, ឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន ស្ថិតនៅភូមិក្រាំងចេក ឃុំដើមឫស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រាកដមែន។

២-ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានទៅទារលុយកម្រៃជើងសារថ្លៃដីចំនួន ១០០$ ដែលជួយរកអ្នកទិញដីឱ្យឈ្មោះ [redacted] អៀន ប៉ុន្តែគាត់មិនបានឱ្យខ្លួនទេ ថែមទាំងបានជេរខ្លួនទៀតផង។ បន្ទាប់មកខ្លួនក៏យកទូរស័ព្ទមកថតសកម្មភាពរបស់ពួកគាត់។ចម្លើយនេះ មានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយជនជាប់ចោទគ្រប់ដំណាក់កាលនៃនីតិវិធី និងស៊ីសង្វាក់ទៅនឹងឯកសារគតិយុត្តិជាភស្តុតាងដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់បានថា នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ ជនជាប់ចោទបានទៅផ្ទះរបស់ឈ្មោះ សុខ សុភ័ក្រ និងឈ្មោះ [redacted] អៀន ដើម្បីទាមទារប្រាក់កម្រៃជើងសារថ្លៃដី ប្រាកដមែន។

៣-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានឆ្លើយដោះសារថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ហើយខ្លួនក៏មិនបានវាយឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន ដែរ។ ចម្លើយនេះ ជនជាប់ចោទគ្រាន់តែឆ្លើយដោះសារឱ្យរួចផុតពីបទចោទប្រកាន់តែប៉ុណ្ណោះ។ បើផ្អែកតាមចម្លើយសាក្សីឈ្មោះ [redacted] អ៊ាន បានបញ្ជាក់ថា ខ្លួនបានឃើញឈ្មោះ [redacted] ប៊ុន យកទូរស័ព្ទមកថត ហើយឈ្មោះ [redacted] អៀន ក៏ចូលទៅឃាត់ បន្ទាប់មកក៏ឈ្មោះ [redacted] ប៊ុន បានវាយឈ្មោះ [redacted] អៀន មួយដៃ។ ក្រោយមកក៏មានការប្រតាយប្រតប់គ្នាទៅវិញទៅមក។ តុលាការពិចារណាឃើញថា ជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានប្រើអំពើហិង្សាទៅលើឈ្មោះ [redacted] អៀន ដែលបានវាយឈ្មោះនេះចំនួនមួយដៃ ចំណែកឈ្មោះ [redacted] សុភ័ក្រ ដែលត្រូវជាកូនឃើញដូចនោះក៏ចូលទៅជួយឪពុកហើយក៏បណ្តាលឱ្យមានការប្រតាយប្រតប់គ្នាទៅវិញទៅមករវាងជនជាប់ចោទទាំងបីនាក់។ ដូច្នេះបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ប៊ុន ពិតជាបានប្រព្រឹត្តអំពើហិង្សាទៅលើឈ្មោះ [redacted] អៀន និងឈ្មោះ [redacted] សុភ័ក្រ ប្រាកដមែន។

៤-ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន បានឆ្លើយដូចគ្នាថា៖ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១១ព្រឹក ខ្លួនបានឃើញឈ្មោះ [redacted] ប៊ុន ជិះម៉ូតូចូលមកផ្ទះខ្លួនដើម្បីទារលុយកម្រៃជើងសារចំនួន ១០០$ ពីឪពុកខ្លួនឈ្មោះ [redacted] អៀន តែគាត់មិនឱ្យ។ បន្ទាប់មកក៏មានការទាស់ពាក្យសម្តីគ្នា។ ក្រោយមកឈ្មោះ [redacted] ប៊ុន បានយកទូរស័ព្ទមកថតសកម្មភាពក្នុងផ្ទះរបស់ខ្លួន ពួកខ្លួនក៏បានរារាំង និងឃាត់។ ចម្លើយនេះ មានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយជនជាប់ចោទគ្រប់ដំណាក់កាលនៃនីតិវិធី ស៊ីសង្វាក់នឹងឯកសារជាភស្តុតាងដែលកសាងឡើងដោយមន្ត្រី



Scanned with CamScanner

នគរបាលយុត្តិធម៌ បញ្ជាក់បានថា នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] ប៊ុន ពិតជាបានទៅផ្ទះរបស់អ្នកទាំងពីរនាក់ដើម្បីទារប្រាក់កម្រៃជើងសារថ្លៃដី រួចក៏បង្កឱ្យមានការទាស់ពាក្យសម្ដីគ្នាឈានដល់ការវាយប្រតាយប្រតប់គ្នាទៅវិញទៅមក ប្រាកដមែន។

៥-ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន បានឆ្លើយដោះសារថា៖ ខ្លួនមិនបានវាយឈ្មោះ [redacted] ប៊ុន នោះទេ។ ចម្លើយនេះ ជនជាប់ចោទទាំងពីរនាក់គ្រាន់តែឆ្លើយដោះសារឱ្យរួចផុតពីបទចោទប្រកាន់តែប៉ុណ្ណោះ។ បើផ្អែកតាមរបាយការណ៍បញ្ជាក់រឿងហេតុ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ របស់មន្ត្រីនគរបាលយុត្តិធម៌ បានបញ្ជាក់ថា ឈ្មោះ [redacted] អៀន បានទាត់ឈ្មោះ [redacted] ប៊ុន ចំនួនបីទៅបួនជើងចំខ្នង ចំណែកឈ្មោះ [redacted] សុភ័ក្រ បានវាយប្រាំមួយដៃ និងទាត់ចំភ្លៅចំនួនបីជើង ហើយក៏មានអ្នកមកជួយឃាត់បំបែកចេញ។ ដូច្នេះបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន ពិតជាបានប្រើហិង្សាទៅលើជនជាប់ចោទឈ្មោះ [redacted] ប៊ុន ប្រាកដមែន។

៦-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុន, ឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន បានវាយប្រតាយប្រតប់គ្នាទៅវិញទៅមកបណ្ដាលឱ្យមានរបួសស្នាមរៀងៗខ្លួន ដែលអំពើនេះជាបទល្មើសព្រហ្មទណ្ឌបទៈ ហិង្សាដោយចេតនា (ទៅវិញទៅមក) ដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៧-តំណាងអយ្យការ បានធ្វើសេចក្ដីសន្និដ្ឋាន៖ តម្កល់ដីកាសន្និដ្ឋានស្ថាពរលេខៈ ១០៣២ ដកសព ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ទុកជាបានការដដែល និងប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការនឹងពិចារណាសម្រេចតាមការប្ដឹងសុំនេះ។

៨-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីរបស់ខ្លួនមិនបានវាយទៅលើឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន ឡើយ។ កូនក្ដីខ្លួនចង់គ្រាន់តែដើម្បីទាមទារឱ្យអ្នកទាំងពីរប្រគល់ប្រាក់កម្រៃជើងសារមកឱ្យកូនក្ដីរបស់ខ្លួន។ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្ដីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់។ តុលាការពិចារណាឃើញថា មិនមានភស្តុតាងណាមួយអាចឱ្យតុលាការសម្រេចតាមការស្នើសុំបានឡើយ ព្រោះជនជាប់ចោទទាំងបីនាក់គឺបានប្រើហិង្សាលើគ្នាទៅវិញទៅមក ហើយក៏មានរបួសស្នាមរៀងៗខ្លួនផងដែរ។ ហេតុនេះតុលាការនឹងពិចារណាលើការដាក់ទណ្ឌកម្មលើជនជាប់ចោទតាមអំពើប្រព្រឹត្តរបស់ជនជាប់ចោទរៀងៗខ្លួន។

៩-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន បានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ឈ្មោះ [redacted] ប៊ុន បានវាយកូនក្ដីរបស់ខ្លួនទាំងពីរនាក់។ កាលដែលឈ្មោះ [redacted] ប៊ុន ថាវាយគាត់ត្រូវដៃ គឺឈ្មោះ [redacted] អៀន មិនអាចវាយបានទេ ព្រោះគាត់មានវ័យចំណាស់ហើយដែរ។ តុលាការពិចារណាឃើញថា មិនមានភស្តុតាងណាមួយអាចឱ្យតុលាការសម្រេចតាមការស្នើសុំបានឡើយ ព្រោះជនជាប់ចោទទាំងបីនាក់គឺបានប្រើហិង្សាលើគ្នាទៅវិញទៅមក ហើយក៏មានរបួសស្នាមរៀងៗខ្លួនផងដែរ។ ហេតុនេះតុលាការនឹងពិចារណាលើការដាក់ទណ្ឌកម្មលើជនជាប់ចោទតាមអំពើប្រព្រឹត្តរបស់ជនជាប់ចោទរៀងៗខ្លួន។

១០-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន, ឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន ជានីតិជនមានស្មារតីគ្រប់គ្រាន់អាចទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនមិនមានភស្តុតាងណាមួយបង្ហាញថាជនជាប់ចោទមានវិបល្លាសស្មារតីឡើយ។ ដូចនេះជនជាប់ចោទមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ។

១១-ក្រោយពីបានពិនិត្យ និងពិចារណាលើភស្តុតាង និងរាល់សេចក្ដីសន្និដ្ឋានរបស់ភាគីតុលាការប្រកាសថាៈ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ប៊ុន, ឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន ពីបទៈ ហិង្សាដោយចេតនា(ទៅវិញទៅមក) ប្រព្រឹត្តនៅភូមិក្រាំងចេក ឃុំដើមឫស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

១២-អំពើដែលជនជាប់ចោទប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកដទៃ ប៉ះពាល់ដល់របៀបរៀបរយ ប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់រដ្ឋ។

១៣-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន, ឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន ទើបតែប្រព្រឹត្តបទមជ្ឈិមលើកទី១ មិនធ្លាប់មានទោសពីមុនមក របួសតិចតួច និងបានជាសះស្បើយអស់ហើយ។ ម្យ៉ាងទៀតអំពើនេះមិនបានប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ សន្តិសុខសង្គមធ្ងន់ធ្ងរនោះទេ គប្បីតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទដោយទោសនេះត្រូវអនុវត្តព្យួរទោសធម្មតា ស្របតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

១៤-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុន បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទាមទារសំណងជម្ងឺចិត្ត ចំនួន ២០,០០០$(ពីរម៉ឺន)ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន។ ឃើញថា ការទាមទារនេះមានចំនួនច្រើនពេក ហើយអ្នកទាំងអស់គ្នាសុទ្ធតែទទួលរងនូវព្យសនកម្មរៀង១ខ្លួន ដូច្នេះតុលាការនឹងសម្រេចតាមសភាពជាក់ស្តែង និងសមហេតុផល។

១៥-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អៀន បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទាមទារសំណងជម្ងឺចិត្ត ចំនួន ៤០,០០០,០០០៛(សែសិបលាន)រៀល ពីជនជាប់ចោទឈ្មោះ [redacted] ប៊ុន។ ឃើញថា ការទាមទារនេះមានចំនួនច្រើនពេក ហើយអ្នកទាំងអស់គ្នាសុទ្ធតែទទួលរងនូវព្យសនកម្មរៀង១ខ្លួន ដូច្នេះគប្បីតុលាការនឹងសម្រេចតាមសភាពជាក់ស្តែង និងសមហេតុផល។

១៦-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក្រ មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទាមទារសំណងជម្ងឺចិត្ត ពីជនជាប់ចោទឈ្មោះ [redacted] ប៊ុន។ ដូច្នេះគប្បីតុលាការមិនពិចារណាដល់បញ្ហានេះឡើយ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] ប៊ុន ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១(មួយ)ឆ្នាំ ដោយទោសនេះត្រូវអនុវត្តព្យួរទោសធម្មតា។

ខ-ឈ្មោះ [redacted] សុភ័ក្រ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១(មួយ)ឆ្នាំ ដោយទោសនេះត្រូវអនុវត្តព្យួរទោសធម្មតា។

គ-ឈ្មោះ [redacted] អៀន ភេទប្រុស អាយុ៦១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១(មួយ)ឆ្នាំ ដោយទោសនេះត្រូវអនុវត្តព្យួរទោសធម្មតា។

ពីបទ: **ហិង្សាដោយចេតនា(ទៅវិញទៅមក)** ប្រព្រឹត្តនៅភូមិក្រាំងចេក ឃុំដើមឫស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៧ និងតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន រួមគ្នាសងសំណងជម្ងឺចិត្តចំនួន ៤,០០០,០០០៛ (បួនលាន)រៀល មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុន។ បណ្តឹងទាមទារពីលើសពីនេះច្រានចោល។

៣-បង្គាប់ឲ្យឈ្មោះ [redacted] ប៊ុន សងសំណងជម្ងឺចិត្តចំនួន ២,០០០,០០០៛ (ពីរលាន)រៀល មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អៀន។ បណ្តឹងទាមទារពីលើសពីនេះច្រានចោល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុន, ឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] អៀន និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤។ ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ
កណ្តាល,ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤
**ចៅក្រមជំនុំជម្រះ**
[redacted]

ថ្ងៃសុក្រ ១២រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
កណ្តាល, ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤
**ក្រឡាបញ្ជីសវនាការ**
[redacted]



Scanned with CamScanner